# តំបន់ "ស "ព្រំដែន

អ្វីទៅដែលហៅថាតំបន់"ស"នៅតាមបណ្តោយខ្សែរបន្ទាត់ព្រំដែនខ្មែរ ?

អ្នកដឹកនាំណាជាអ្នកអ្នកបង្កើតតំបន់"ស"នៅតាមបណ្តោយព្រំដែនខ្មែរនេះ ?

តំបន់"ស"គឺជាខ្សែរបន្ទាត់ព្រំដែនខ្លះៗ តាមបណ្តោយព្រំដែនខ្មែរ-យួន, ព្រំដែនខ្មែរ-សៀម, ខ្មែរ-លាវ ដែលប្រទេសទាំងបីនេះ ជាពិសេសប្រទេសយួន យកលេះបង្កើតជាបញ្ហាថាព្រំដែនខ្លះៗនោះមិនច្បាស់លាស់ យើង(ខ្មែរនឹងយួន)ត្រូវតែបង្កើតតំបន់"ស"នេះឡើងដោយឈរលើគោលការណ៏ៈ យួននៅត្រង់កន្លែងណា ខ្មែរនៅកន្លែងណា ត្រូវនៅកន្លែងនោះមិនអាចរុះរើបានឡើយ ។ នេះជាមហិច្ឆិតាលោភលន់ ជាយុទ្ធសាស្ត្រវាតទីលេបទឹកដីរបស់ខ្មែរដែលយួនវាបានអនុវត្តតាមបណ្តាំរបស់ខ្មោច ង្វៀង អៃ ក្វិក ហៅ ហូ ជី មិញ ថាត្រូវតែលេបយកប្រទេសកម្ពុជាឲ្យទាល់តែបាន ។ អ្នកដឹកនាំខ្មែរ មិនស្គាល់ប្រវត្តិសាស្ត្រ មិនស្គាល់ព្រំដែន មិនចេះច្បាប់ជាតិ មិនចេះច្បាប់អន្តរៈជាតិ ឈ្មោះនរោត្តម រណ្ណឫទ្ធិ មានងារជាក្រុមព្រះ ឬ ក្រុមប្រែត មានឋានៈជានាយករដ្ឋមន្ត្រីទី១ទៅបង្កើតតំបន់"ស"នេះឡើងហើយបានចុះហត្ថលេខាជាមួយយួននៅឯក្រុងហាណូយ ក្រោយពីឆ្នាំ ១៩៩៣ ក្រោមការយល់ព្រមរបស់នរោត្តម សីហនុ កាលនោះជាស្តេច"ស្តុចម៏"សោយរាជលើប្រទេសកម្ពុជា ។

តែមកដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ នេះទើប នរោត្តម សីហនុ ប្រកាសថាមិនទទួលស្គាល់តំបន់"ស"នេះទេ ! តើយ៉ាងម៉េច ? ។ សូមឆ្លើយ ? ។ ការមិនទទួលស្គាល់តំបន់"ស"ជាការត្រឹមត្រូវហើយ ! ជាការពេញចិត្តរបស់ប្រជារាស្ត្រខ្មែរហើយ ! ប៉ុន្តែមិនមែនមកប្រកាសមិនទទួលស្គាល់តំបន់"ស"នៅពេលនេះទេ ! ម្នាលនរោត្តម សីហនុ ! ។ ត្រូវម្នាលនរោត្តម សីហនុ ឯងប្រកាសនៅក្នុងចន្លោះឆ្នាំ១៩៩៣-២០០៤ ឯណុះវិញទេទើបគេហៅថាជាអ្នកការពារទឹកដី ការពារព្រំដែនខ្មែរមែន យល់ទេម្នាលនរោត្តម សីហនុ ? ។ ហេតុអ្វីបានជាម្នាលនរោត្តម សីហនុ ឯងយកប្រទេសខ្មែរប្រជាពលរដ្ឋខ្មែរមកលេងសើចយ៉ាងដូច្នេះទៅវិញ ?

ដើម្បីឲ្យខ្មែរខ្លះដែលមិនបានដឹងថាតើហេតុអ្វីបានជា នរោត្តម សីហនុ បានវិលត្រឡប់មកកាន់តំណែងជាប្រមុខរដ្ឋខ្មែរខ្ញុំមយួន ឬ ខ្មែរយៀកមិញ ហើយបានឡើងជាស្តេច (ស្តុចម៏) សោយរាជជាលើកទី២នេះវិញ : ដោយសហភាពសូវៀតរលំរលាយទៅ យួនមិនអាចទ្រាំទ្រចំណាយមកលើការជិះជាន់ប្រទេសខ្មែរបានឡើយ ។ យួនត្រូវរកយុទ្ធសាស្ត្រថ្មីដើម្បីយកប្រទេសខ្មែរឲ្យនៅជាខ្ញុំមក្រោមការត្រួតត្រារបស់វាឲ្យស្របទៅនឹងច្បាប់អន្តរៈជាតិ ។ យួនបានដូរឈ្មោះសាធារណៈរដ្ឋប្រជាមានិតុកម្ពុជា មកជារដ្ឋកម្ពុជាវិញ ។ តើខុសគ្នាយ៉ាងណាដែរពីសាធារណៈរដ្ឋប្រជាមានិតុកម្ពុជាមកជារដ្ឋកម្ពុជា ? គ្មានខុសគ្នាទេ ស្លាបណ៏រដ្ឋនៅដដែល ដូរតែទង់ជាតិ ដូរភ្លេងជាតិ ហើយដក ហេង សំរិន ចេញពីប្រធានរដ្ឋ ទុកឲ្យរដ្ឋកម្ពុជាគ្មានប្រធាន ឬ ប្រមុខរដ្ឋប្រហែលចំនួន៣ឆ្នាំ ដើម្បីទាក់ទាញបញ្ចុះបញ្ចូល នរោត្តម សីហនុ ឲ្យមកធ្វើជាប្រមុខរដ្ឋនៃរដ្ឋកម្ពុជា ។ សាធារណៈរដ្ឋ

ប្រជាមានិតុកម្ពុជាប្តូរមកជារដ្ឋកម្ពុជានៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ ។ រហូតមកដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩១ ទើបទាក់ទាញកាត់ក្បាល នរោត្តម សីហនុ មកដោតលើរដ្ឋកម្ពុជាឲ្យធ្វើជាប្រមុខរដ្ឋនៃរដ្ឋកម្ពុជា រហូតមកដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ថ្ងៃដែលហ៊ុន សែន តែងតាំង នរោត្តម សីហនុឲ្យទៅជាស្តេច ឡើងសោយរាជតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។ សូមបញ្ជាក់ថា នរោត្តម សីហនុ បានដឹកជញ្ជូនប្រពន្ធកូន ចៅចូលមកប្រទេសកម្ពុជាវិញពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ ក្រោយពីយួនដេញកំចាត់គាត់ចេញពីភ្នំពេញពីថ្ងៃ ទី០៦ ខែមករា ឆ្នាំ១៩៧៩ ។ ឥឡូវនេះ (១៩៩១) គាត់វិលត្រឡប់មកធ្វើជាប្រមុខរដ្ឋក្រោមការត្រួតត្រារបស់ យួនវិញដដែលហើយ ។ នេះជារឿងធម្មតារបស់នរោត្តម សីហនុ ទៅហើយ មិនធ្វើឲ្យខ្មែរភ្ញាក់ផ្អើលអ្វីឡើយ ព្រោះគាត់ធ្លាប់តែធ្វើរណបបំរើចិនបំរើយួន គាត់ធ្លាប់បានកាត់ទឹកដីឲ្យទៅយួន គាត់ធ្លាប់បានឲ្យយួនខាងជើង យួនយៀកកុង មកតាំងទីទព័នៅលើប្រទេសកម្ពុជា គាត់ធ្លាប់បានឲ្យទាហានយួនខាងជើង ទាហានយៀកកុង មកកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរ ដុតបំផ្លាញវត្តអារាមផ្ទះសម្បែង លួចប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋខ្មែរ ធ្វើឲ្យ ប្រទេសខ្មែរ ប្រជាជនខ្មែរ វិនាសព្រាត់ប្រាស ហិនហោចខ្ទេចខ្ទីរចុះក្រតាំងពីឆ្នាំ១៩៧០ រហូតមកដល់សព្វ ថ្ងៃនេះ ។

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩១ រដ្ឋកម្ពុជា(សាធារណៈរដ្ឋប្រជាមានិតុកម្ពុជាលាក់មុខ)ព្រមទាំងគណបក្ស ប្រជាជន បានចេញសេចក្តីថ្លែងការណ៏លប់ចោលអ្វីដែលពួកកម្មុយនិសអាយ៉ងយួនហៅថារដ្ឋប្រហារខុសច្បាប់ របស់លន់ ណុល ពីថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ ចោលចេញហើយទទួលស្គាល់នរោត្តម សីហនុ ជាប្រមុខ រដ្ឋប្រទេសកម្ពុជាឡើងវិញ ។ មកដល់ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៩១ ដដែល : Le bureau du président du CNS (CONSEIL NATIONAL SUPRÊME) diffuse un communiqué annonçant que les quatre factions *<<officiellement et solennellement déclarent que Samdech Preah Norodom Sihanouk a été le Chef d'État légitime et de plein droit du Cambodge depuis 1960>>*. (sic)

ក្រោយពីបានឡើងធ្វើជាប្រមុខរដ្ឋនៃរដ្ឋកម្ពុជាហើយ នរោត្តម សីហនុ បានតែងតាំង : ហេង សំរិន, ជា ស៊ីម នឹង ហ៊ុន សែន ឲ្យឡើងងារជា : សំដាចម៏ហេង សំរិន, សំដាចម៏ជា ស៊ីម នឹង សំដាចម៏ ហ៊ុន សែន ដូចពាក្យខ្មែរថា :"ឯងអេះខ្នងឲ្យអញ ! អញអេះខ្នងឲ្យឯងវិញ" ។ បន្ទាប់មកនរោត្តម សីហនុ បានតែងតាំងនរោត្តម រណ្ណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី១ ឯហ៊ុន សែន វិញជានាយករដ្ឋមន្ត្រីទី២ មិនដែលមាន ប្រវត្តិសាស្ត្រនៅលើផែនដីមូលនេះទេ ហេតុដូច្នេះហើយបានជាសៀម,យួន,លាវហ៊ានរំលោភយកទឹកដីខ្មែរតាម ព្រំដែនមកដល់សព្វថ្ងៃនេះ ដោយសារតែនរោត្តម សីហនុ ចោលម្សៀត ឆ្កួតលីលា មិនដឹងខុស មិនដឹងត្រូវ មានមហិច្ឆិតាសួនតួ លោភលន់ ចង់ធ្វើតែជាប្រមុខរដ្ឋ ឬ ជាស្តេច (ស្តាចម៏) អស់មួយជីវិត លើកតំកើងតែ

គ្រួសារឯង តែងតាំងម៉ូនីកពីសាហាយរហូតជាព្រះមហាអគ្គមហេសី,រហូតដល់ព្រះមហាវរៈមាតាជាតិខ្មែរ ។ តែងតាំងកូនរបស់ឯងឲ្យមានងារ ជាក្រុមព្រះឬក្រុមប្រែត, ក្រុមឃុនឬក្រុមខ្វូច, ក្រុមហ្លួងឬក្រុមល្វូច, ជាស្ដេចអាយ, ជាស្ដេចអ្វូច, ជាស្ដេចអ្វូក, ជាស្ដេចអុយ, ជាស្ដេចអុក, ។ល។នឹង។ល។ នរោត្តម សីហនុ បើកដៃឲ្យម្ដាយក្មេកឈ្មោះប៉ុម ពាង នឹង ប្រពន្ធចុងឈ្មោះអ៊ីស៊ី ម៉ូនីក ប្រព្រឹត្តអំពើពុករលួយ ជួលដីឲ្យយួនខាងជើងយួនយៀកកុង ស៊ីឈ្នួលដឹកគ្រឿងសម្ភារៈសឹកយកទៅប្រគល់ឲ្យទាហានយួនខាងជើងនឹងទាហានយៀកកុងនៅតាមបណ្ដោយព្រំដែនខ្មែរ-យួន ដោយយកកម្លាំងកងខេមរៈភូមិន្ទមកបំរើមហិច្ឆិតារបស់ខ្លួនដោយអត់គិតថ្លៃ ។ ក្នុងទសវត្សរ៍ទី៦០ ប៉ុម ពាង នឹង អ៊ីស៊ី ម៉ូនីក ប្រមូលប្រាក់បាន ២៥០.០០០.០០០ រៀល ពីយួនខាងនឹងយួនយៀកកុង ក្នុងមួយខែៗ ប្រហែល ៨០០.០០០ ដុល្លាអាមេរិក ។ សូមស្ដាប់សេចក្ដីប្រកាស :

Bernard Hamel dans le website : http://amekhmer.free.fr en cliquant sur Sihanouk, la machine à tuer .

ក្រោយពីបានតែងតាំងនរោត្តតម រណ្ណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី១ នឹង ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២ ឲ្យបំផ្លាញជាតិរួចមក ដល់វេនអាយ៉ងយួនតែងតាំង ឬ ជប់ នរោត្តម សីហនុ ឲ្យទៅស្ដេច (ស្ដាចម៉ិល្ខេនបាសាក់) ឡើងសោយរាជជាលើកទី២លើនគរកម្ពុជា កាលពីថ្ងៃទី២៤ កញ្ញា ឆ្នាំ១៩៩៣ ។

នរោត្តម សីហនុ ធ្វើជាប្រមុខរដ្ឋលើកចុងក្រោយនេះអស់រយៈកាល៣ឆ្នាំ គឺពី១៩៩១ ដល់១៩៩៣ ។ សិទ្ធិសញ្ញានៅក្រុងប៉ារីសពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩៣ បានបញ្ជាក់ថារាល់សិទ្ធសញ្ញាជាមួយប្រទេសជិតខាងពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩៣ ដែលធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៏, បាត់បង់អធិប្បតេយ្យភាព, បាត់បង់បូរណៈភាពទឹកដីនៃប្រទេសកម្ពុជា ត្រូវទុកជាមោឃៈ ។ ពេលនោះនរោត្តម សីហនុ មានអំណាចចុកគួជ ។ ហេតុអ្វីបានជានរោត្តម សីហនុ មិនលប់សិទ្ធិសញ្ញាខុសច្បាប់ជាមួយយួនពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ មានជាអាទិគឺ

Le traité de Paix, d’Amitié et de Coopération avec la République socialiste du Vietnam du 18 Février 1979

L’accord sur la zône des eaux historiques avec la République socialste du Vietnam du 07 Juillet 1982.

L’accord sur le statut frontalier avec la République socialiste du Vietnam du 20 Juillet 1983.

Le traité sur la délimitation de la frontière avec la République socialiste du Vietnam du 27 Décembre 1985.

លុះមកដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ពួកអាយ៉ងយួនៈ មានហេង សំរិន, ជា ស៊ីម, ហ៊ុន សែន បើកភ្លើងពណ៏បៃណង តែងតាំងជប់នរោត្តម សីហនុ ឲ្យកើតទៅជាស្ដេច (ស្ដាចម៉ិ) ឡើងសោយរាជលើនគរកម្ពុជា រហូតមកដល់ថ្ងៃ២៧ ខែតុលា ឆ្នាំ២០០៤ មានរយៈកាល ១០ឆ្នាំ ។ នរោត្តម សីហនុ ជាស្ដេចសោយរាជលើទី២នេះ ស្ថិតនៅក្រោមច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។ ត្រង់មាត្រា០៨នៃច្បាប់រដ្ឋធម្មនុញ្ញនេះបានចែង (ជាភាសាអង់គ្លេស) ថា :

A R T I C L E : 08 :

-The King of Cambodia shall be a symbol of unity and eternity of the Nation.

-The King shall be the guarantor of the national Independance, Sovereignity and territorial Integrity of the Kingdom of Cambodia, the protector of rights and freedom for all citizens and the guarantor of international treaties .

នៅក្រោមមាត្រា០៨នេះ នរោត្តម សីហនុ មានបុព្វសិទ្ធិ នឹង អំណាចគ្រប់គ្រាន់ដើម្បីការពារបូរណៈភាពទឹកដី ព្រំដែនប្រទេសកម្ពុជា ។ ហេតុអ្វីបានជានរោត្តម សីហនុ មិនលប់សិទ្ធិសញ្ញាខុសច្បាប់ខាងលើនេះពី១០ឆ្នាំមុននេះចោលចេញជាស្ថាពរទៅ ? ។ ហេតុអ្វីបានជានរោត្តម សីហនុ មកលើកកំពស់ខ្លួនឯងបញ្ចេញពឹសដូចពស់ប្រលិត ហើយមកស្រែកថាមិនទទួលស្គាល់សិទ្ធិសញ្ញាពីឆ្នាំ១៩៧៩, ១៩៨២, ១៩៨៣ នឹង ១៩៨៥ ព្រមទាំងប្រកាសមិនទទួលស្គាល់តំបន់ ” ស ” នៅតាមបណ្តោយព្រំដែនខ្លះៗ ដែលកូនរបស់ខ្លួនឈ្មោះនរោត្តម រណ្ណឫទ្ធិ បានបង្កើតឡើងឲ្យមានបញ្ហារហូតមកដល់សព្វថ្ងៃនេះ ? ។

ឯស្តេច (ស្តាចម៉ិ) នរោត្តម សីហមុនី ជាកូនប្រុសរបស់នរោត្តម សីហនុ ដែលហ៊ុន សែន ទើបតែនឹងតែងតាំងឲ្យធ្វើជាស្តេចសោយរាជពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤មុននេះក៏ស្ថិតនៅក្រោមមាត្រា០៨នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដូចនរោត្តម សីហនុដែរ ។ ម្តេចក៏ស្តេចនរោត្តម សីហមុនី មិនលប់សិទ្ធិសញ្ញាខាងលើនេះឲ្យចប់បញ្ហាខាតបង់ទឹកដីនោះចោលទៅ ? ហេតុអ្វីបានជាស្តេចនរោត្តម សីហមុនី ទៅបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់កិច្ចការព្រំដែនដោយបានតែងតាំងឪរបស់ខ្លួនឯងឈ្មោះនរោត្តម សីហនុ ឲ្យធ្វើជាប្រធានឥតប្រយោជន៏, បង្ខាតប្រាក់កាសរដ្ឋទៅវិញយ៉ាងដូច្នេះ ? ។ នេះសមនឹងពាក្យខ្មែរថាប្រាក់ក៏បង់ ថង់ក៏ដាច បានសេចក្តីថា:ប្រជាពលរដ្ឋខ្មែរចិញ្ចឹមស្តេចរាប់រយឆ្នាំមកហើយបង្ខាតតែបាយ ប្រទេសកម្ពុជានៅតែបាត់បង់ទឹកដីបន្តិចម្តងៗ រួញមកនៅប៉ុណសព្វថ្ងៃក៏ដោយសារក្រុមពួកស្តេចធ្វើឲ្យបាត់ ។

តើខ្មែរនៅសង្ឃឹមទៅលើ នរោត្តម សីហនុ, នរោត្តម សីហមុនី, នរោត្តម រណ្ណឫទ្ធិ អាចដោះស្រាយទំនាស់ព្រំដែនជាមួយសៀម, យួន, លាវ បានជាស្ថាពរឬ ? កុំសង្ឃឹមឲ្យសោះ ? ព្រោះអ្នកទាំងបីនាក់នេះបានឡើងធ្វើស្តេច, បានឡើងធ្វើប្រធានរដ្ឋសភា ដោយការតែងតាំងរបស់អាយ៉ងយួន ហ៊ុន សែន ! ។ យួន (អាយ៉ងយួនហ៊ុន សែន) ជាអ្នកបង្កើតស្តេច ជាអ្នកឲ្យលាភសការ:ឲ្យស្តេចទាំងបីនាក់នេះ ។

ដូច្នេះ ចង់ឬមិនចង់ ស្តេចអុយទាំងបីព្រះអង្គនេះ (ឪពុកនឹងកូន) ស្ថិតនៅក្រោមខ្សែរញាក់សំដាចម៉ិហ៊ុន សែន មិនអាចប្រកែកបានឡើយ ហើយមិនអាចធ្វើអ្វីជាប្រយោជន៏សម្រាប់ប្រទេសខ្មែរបានឡើយ ៕

ភ្នំពេញ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៥

**ខែម ខៀវ**